**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ ទេសចរណ៍ និងកាពយន្ត ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល

**( លើកទី៧២ )**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៣ ៦៩៦នាក់ នៃ រោងចក្រ សហគ្រាសទាំង៣០ នៃវិស័យកាត់ដេរ វិស័យទេសចរណ៍ និងវិស័យកាពយន្ត (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះ ទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាសទាំង៣០ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមប្រញាប់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ ពុធ ១៤កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០២១

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣) ៨៨ ៨៣ ៧៥ និងទូរសារៈ(០២៣) ៨៨ ២៧ ៦៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១

បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ វិស័យទេសចរណ៍ និងវិស័យគាពយន្ត
ចំនួន ៣០ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 4 |
| 1 | ក្រុមហ៊ុន ម៉ាកស៍វ្វ ថេកស្ពាយ (ខេមបូឌា) ខូអិលធីឌី | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ប្រាយ ហ្វាស់ស៊ីង ឯ.ក | តាកែវ |
| 3 | ក្រុមហ៊ុន ហ្គ្រេសហ្វុល(ខេបូឌា)ថេកស្ពាយ ខូ.អិលធីឌី | តាកែវ |
| 4 | ក្រុមហ៊ុន កៅវេ ស្ព័ត អិលធីឌី | ស្វាយរៀង |
| ខ. វិស័យទេសចរណ៍ | | 22 |
| 5 | ក្រុមហ៊ុន ឡឺ ប្រេស៊ីដង់អូតែល-កូបេ | ភ្នំពេញ |
| 6 | ក្រុមហ៊ុន អិល&អិម បាសាក់ រីវើរ ខូ អិលធីឌី | ភ្នំពេញ |
| 7 | ក្រុមហ៊ុន អលមិន ខូ អិលធីឌី | ភ្នំពេញ |
| 8 | សណ្ឋាគារ រ៉េស៊ីដង់ សុខាភ្នំពេញ | ភ្នំពេញ |
| 9 | ក្រុមហ៊ុន រ៉ាហ្វលមហាសណ្ឋាគារអង្គរ | សៀមរាប |
| 10 | សណ្ឋាគារសុខាសៀមរាប | សៀមរាប |
| 11 | ក្រុមហ៊ុន ផ្កាហ្សា ព្រីម្យៀ ឡូញ (ខេមបូឌា) សាខាសៀមរាប | សៀមរាប |
| 12 | ក្រុមហ៊ុន កាឡាស ខម(ខេមបូឌា)ភីធីអុី អិលធីឌី (សណ្ឋាគារ អង្គរ អេរ៉ា) | សៀមរាប |
| 13 | ក្រុមហ៊ុន ទន្លេសាបចៅផាយ៉ា( អង្គរធីខេត្រាវែល ធួរ) | សៀមរាប |
| 14 | សណ្ឋាគារ លីនាយាអង្គរ រីសត និងស្ប៉ា | សៀមរាប |
| 15 | ក្រុមហ៊ុន បុរី អង្គរ | សៀមរាប |
| 16 | សណ្ឋាគារ យើងដុម អង្គរ | សៀមរាប |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 17 | សណ្ឋាគារតាព្រហ្ម | សៀមរាប |
| 18 | សណ្ឋាគារ វិរតន៍ | សៀមរាប |
| 19 | ក្រុមហ៊ុន ដំរីអង្គរ ខូ អិលធីឌី | សៀមរាប |
| 20 | ក្រុមហ៊ុន ផ្កាចន្ទន៍ សៀមរាប យ៉ុងឆាង | សៀមរាប |
| 21 | ក្រុមហ៊ុន វិរតន៍ វីឡា | សៀមរាប |
| 22 | សណ្ឋាគារ សិន្ថា មុន្នី | សៀមរាប |
| 23 | ក្រុមហ៊ុន ឡូទុស ប្លង្គ រីសត | សៀមរាប |
| 24 | ក្រុមហ៊ុន អេប៉ិច ខេមបូឌា ត្រាវ៉ែល ស៊ែរវីស | សៀមរាប |
| 25 | ក្រុមហ៊ុន បាហ្វឺឡូធូរ (ខេមបូឌា) លីមីតធីត | សៀមរាប |
| 26 | រមណីយដ្ឋានឆ្នេរសុខា | ព្រះសីហនុ |
| គ. វិស័យភាពយន្ត | | 4 |
| 27 | ក្រុមហ៊ុន មេជើរ ផ្លេធីណឹម ស៊ីនេផ្លិច (ខេមបូឌា) | ភ្នំពេញ |
| 28 | ក្រុមហ៊ុន យូជេនេថេកខេមបូឌ ឯ.ក(សាខា ចោមចៅ) | ភ្នំពេញ |
| 29 | ក្រុមហ៊ុន យូជេនេថេកខេមបូឌា ឯ.ក(សាខា ទួលគោក) | ភ្នំពេញ |
| 30 | ក្រុមហ៊ុន លេជេន ស៊ីណេម៉ាខូអិលធីឌី | ភ្នំពេញ |